...នាឡិកាប៉ោលបញ្ចេញសូរសម្លេងតិកតុកៗលើជញ្ជាំង។

ចម្លែកបន្តិចហើយ ដែលសំឡេងដ៏តូចឆ្មារប៉ុណ្ណឹងអាចរំខានដំណេករបស់គេ... ឬមួយមកពីបេះដូងគេ កំពុងត្រូវរំខានដោយបញ្ហាអ្វីផ្សេង?

...យប់ណាស់ទៅហើយ..... គេហាក់មិនអាចបង្ខំខ្លួនឯងឱ្យបន្តគេងទៀតបានទេ ។ ការគេងមិនលក់ ហើយខំប្រឹងដោយបង្ខិតបង្ខំ វាក្លាយជាស្ថានភាពដ៏តប់ប្រមល់មួយប៉ះពាល់ទាំងផ្លូវកាយ និងផ្លូវអារម្មណ៍។

...គេក្រោកឈរថ្នមៗ បង្អួតរាងកាយខ្ពស់ស្រលះ ជាមួយដៃដ៏រហ័សដែលទាញអាវរាត្រីមកគ្របពីក្រៅប្រឆាំងនឹងភាពត្រជាក់នៃរាត្រីកាល។

មុនពេលរំកិលខ្លួនចេញពីបន្ទប់នោះ គេរវេ្ទកប្រទះឃើញភរិយាតូចច្រឡឹងក្នុងផ្ទាំងកញ្ចក់។ នាងកំពុងលង់លក់ស្កប់ស្កល់លើគ្រែដែលគេទើបតែក្រោកចេញមកនេះ។
ទោះបីជាភ្នែកនាងទាំងគូបិទជិត នៅសល់តែដងចិញ្ចើមខ្វង់ដូចឥន្ទធនូ ក៏ភាពស្រស់ស្អាតរបស់នាងបានគ្របដណ្តប់បន្ថែមពីលើអាវសរសៃសូត្រដ៏ទន់ល្មែរលោងស្រិលនោះទ្វេដង។

ប្តីម្នាក់នេះគួរតែសប្បាយចិត្តពេលឃើញភរិយាស្រស់ផូរផង់របស់ខ្លួន មិនសមថាកែវភ្នែកគេទាំងទ្វេបែរជាស្រពាប់ស្រពោនសោះ។ គេចាកចេញមករកបន្ទប់ធំទូលាយក្បែរនោះដែលមានទូសៀវភៅជាច្រើននៅអមប្របសងខាងជញ្ជាំង។

ប៉ុន្តែគោលដៅរបស់គេឆ្ពោះទៅរកកុំព្យូទ័រ និងតុធ្វើការឯជ្រុងខាងត្បូង។

គេបើករកឯកសារមួយដែលបានអានពាក់កណ្តាលកាលពីពេលមុន ពេលនេះទើបនឹងនឹកឃើញចង់អានបន្ត។

ពន្លឺស្រអាប់ក្នុងបន្ទប់នេះបានបញ្ចេញនូវភាពអាថ៌កំបាំងលើផ្ទៃមុខគេ។ គេជាមេធាវីដ៏មានជំនឿចិត្ត។ គេធំធាត់ឡើងនៅសហរដ្ឋអាមេរិក មានឱកាសទទួលបានចំណេះដឹង និងការងារល្អ ចុងក្រោយក៏បានរៀបការជាមួយធីតាមកពីគ្រួសារអ្នកមានស្តុកនៅភ្នំពេញ។ វិថីជីវិតរបស់គេក្រាលដោយមាស និងភាពរុងរោចន៍ ចុះហេតុអ្វីក៏អារម្មណ៍គេប្តូរទៅជាចម្លែកនៅពេលសម្លឹងទៅរកអ្វីមួយលើអេក្រង់?

...បន្ទាប់មក បបូរមាត់គេលេចចេញនូវសំណើច សោះកក្រោះ មើលស្រាល....
«សំណុំរឿង ស្ទូឌីយោលេខ៧?.... ក្តីកំបិុកកំប៉ុក!»

រអ៊ូបណ្តើរ គេកម្រើកដៃបញ្ជាវាយកុំព្យូទ័រចុះឡើងផង។

ចិញ្ចៀនអាពាហ៍ពិពាហ៍របស់គេចោលរស្មីភ្លឺរន្ទាលលើម្រាមនាងដៃ ដែលគេប្រើវាលើកុំព្យូទ័រយ៉ាងស្ទាត់ជំនាញ។

អក្សរមួយចំនួនលេចឡើងលើ Chat របស់គេ....
«ប្រពន្ធលោក មានផ្ទះតូចមួយនៅកំពង់សោម! តាំងពីរៀបការជាមួយលោក គាត់មិនដែលទៅទីនោះទេ ប៉ុន្តែម្តងម្កាលធ្លាប់មានគេឃើញអ្នកបម្រើប្រុសឈ្មោះសួសទៅចាក់សោបោសសំអាតផ្ទះនោះ!»
គេសញ្ជឹងគិតស្ងប់ស្ងាត់ តែដៃគេរហ័សរហួន។ គេចុចសួរតបនូវសំណួរមួយចំនួន...
«ចម្លែកត្រង់ណា? គ្រួសារភីណាជាអ្នកមានច្រើនជំនាន់មកហើយ! គេមានផ្ទះជាច្រើននៅតាមតំបន់ទេសចរណ៍សំខាន់ៗគឺជារឿងធម្មតា មានអីគួរឱ្យចាប់អារម្មណ៍ទៅ?»
«ប៉ុន្តែមុនពេលនាងរៀបការជាមួយលោក គឺក្រោយពេលដែលបងប្រុសនាងឈ្មោះកុសលចូលពន្ធនាគារ នាងធ្លាប់ត្រឡប់មកស្រុកខ្មែរ ហើយទៅស្នាក់នៅទីនេះច្រើនដងណាស់!»
«មកពីភីណាចូលចិត្តហែលទឹក!»
«ប៉ុន្តែនាងមកនៅក្នុងពេលដែលអតីតគូដណ្តឹងនាងនៅជាប៉ូលិសនៅកំពង់សោម! គឺក្នុងពេលដែលគេកំពុងល្បីឈ្មោះជាមួយនឹងការបំបែករឿងក្តីមនុស្សឃាតលើស្រីពីរនាក់នៅស្តូឌីយោលេខ៧!»
គេនៅស្ងៀម ហើយភាពស្ងប់ស្ងៀមនៅតែអូសបន្លាយ។ តែទោះយ៉ាងណា គេមិនអាចលាក់លៀមការត្រិះរិះ ក៏ដូចជាការចាប់អារម្មណ៍យ៉ាងជ្រាលជ្រៅទៅនឹងរបកគំហើញនេះទេ។
គេកំពុងគិតថា តើបន្ទាប់ពីនាយប៉ូលិសរិទ្ធបានបញ្ចប់សំណុំរឿងម៉ោង១២អធ្រាត្រនៅសង្កាត់លេខមួយរួចហើយ ភីណានៅមិនទាន់ដាច់អាល័យពីគូដណ្តឹងរូបនេះទាំងស្រុង? នាងពិតជាត្រឡប់មកកម្ពុជាស្ងាត់ៗ ហើយទៅសម្រាកនៅទីនោះ?
«ផ្ទះនោះនៅម្តុំណា?!»
«ស្ទឹងហាវ?!»
«ខ្ញុំមិនស្គាល់តំបន់នោះទេ!»
«តែបួនប្រាំគីឡូម៉ែត្រពីទីរួមខេត្តព្រះសីហនុ!»
គេលែងចេញស្តីជុំវិញការស្រងាកចិត្តមួយដែលហាទៅស្លាក់ ខ្ទាក់ក៏ស្លែង។ ម៉េចមិនដែលឮនាងរំលឹកប្រាប់? បងប្រុសនាងឈឺស្លាប់ក្នុងពន្ធនាគារតាំងពី២ឆ្នាំមុន ហេតុអ្វីនាងរក្សាអចលនវត្ថុអស់នោះដល់ណា បើនាងមិនដែលនិយាយថាចង់វិលមករស់នៅស្រុកខ្មែរវិញផង?
សំណួរជាច្រើនរុកកួនបេះដូងគេ ពិសេសគឺសំណួរចុងក្រោយមួយ....
«រយៈពេលនោះ តើនាងនិងគូដណ្តឹងជាប៉ូលិសនោះដែលជួបគ្នាទៀតដែរឬទេ?!»
គេសួរខ្លួនឯងក្នុងចិត្តស្ងាត់ៗ។
ទោះបីជាគេមិនទាន់មានសំណួរសួរទៅបន្ត តែភាគីម្ខាងទៀតបានសរសេរមកបន្ថែម៖
«លោកចាំមើលទៅ! ដែលភរិយាលោកមកភ្នំពេញលើកនេះ នាងទៅលេងទីនោះទៀតដែរឬក៏អី? បើ

នាងនិងប៉ូលិសនោះចប់រឿងរ៉ាវមែន នាងឧស្សាហ៍ទៅទីនោះធ្វើអី?!»

«ប៉ុណ្ណឹងចុះ! ខ្ញុំត្រូវការសម្រាក!»

គេចុចឆាតបិទ ព្រោះបេះដូងចាប់ផ្ដើមលោតញាប់។

បបូរមាត់គេសោះកក្រោះ ហើយភាពច្រណែនប្រចណ្ឌបានបុកទម្លុះចំណេះដឹង និងសមត្ថភាពគ្មានព្រំដែនរបស់គេ។

គេក្រឡេកមកមើលកុំព្យូទ័រដែលដៃគេកំពុងបញ្ជាឱ្យបង្ហាញមុខនាយប៉ូលិសវ័យក្មេងច្បាស់ទៃងនោះ។

«ឧត្តមសេនីយ៍ វិទូ!»

គេអានឈ្មោះនេះតិចៗ ហើយកែវភ្នែកបញ្ចេញភាពមើលស្រាល។

ត្រូវហើយ នេះជាចរិតពិតរបស់គេ ក្រៅស្រស់សង្ហា មានយកកេរ្តិ៍ឈ្មោះ ហើយមានទ្រព្យធន គេក៏ជាអ្នកច្បាប់វ័យក្មេងដែលមានអំនួត និងពិបាករកគូប្រជែង។

គេគឺមេធាវី វង្ស ជំនិត ដែលមានឈ្មោះហៅក្រៅថា Frank ។

# មនុស្សអតីតបង្ហាញខ្លួន

«បងត្រូវទៅនៅកំពង់សោមបីបួនថ្ងៃ!»

«មានការអី ក្រែងថាមកស្រុកខ្មែរមកដើរលេងសុទ្ធសាធហ្អី?!»

«ដីដូនមួយបងមានបញ្ហាដីធ្លីតិចតួច ត្រូវការបងជួយទៅពិនិត្យលិខិតស្នាម! អូនមានស្គាល់អូតែលណាល្អដែរទេ?! បើអត់ទេ បងកក់តាមOnline!»

ភីណាផាត់សក់ពណ៌មាសវែងអន្លាយ ហើយទន់ល្មៃ វែងឱ្យរំលងទៅម្ខាង នឹងអាលនាងឱនមកក្រេបកាហ្វេក្នុងពែង មុនពេលងើបមុខមកគ្រវីក្បាល ឆ្លើយតបនឹងស្វាមី៖

«Booking.com ប្រហែលមានជម្រើសច្រើន! អូនខានមកស្រុកខ្មែរជាងមួយឆ្នាំហើយ ប្រហែលជាគេមានអូតែលល្អៗ យើងមិនស្គាល់ផងមិនដឹង!»

នាងបន្តបរិភោគអាហារពេលព្រឹក ក្រោមខ្សែភ្នែកស្មើធេងរបស់ប្តី។

នាងមិនដឹងឡើយថាអ្វីៗដែលអ្នកស៊ើបឯកជនប្រាប់មកជំនិតកាលពីយប់មិញ បានធ្វើឱ្យគេសៅហ្មងរហូតដល់ព្រឹកនេះ។

គេសម្លឹងទម្រង់មុខដ៏ស្រស់ស្អាតរាងទ្រវែងពងក្រពើ ហើយនិងបបូរមាត់ពណ៌ក្រហមស្រាលពីធម្មជាតិគ្មានគ្រឿងក្រែមម្សៅរបស់នាង មុនពេលគេសាកល្បងពោលបន្ថែម៖

«បើយើងមានកូនផ្ទះមួយនៅទីនោះ កាន់តែល្អហើយ!»

ពន្លឺខ្សោយស្រទន់នៃកែវភ្នែកទាំងសងរបស់នាងតម្រង់មករកគេជាមួយស្នាមញញឹមលាយភាពងឿងឆ្ងល់។ នាងមិនទាន់និយាយពីគំនិតនាងផង គេពោលបន្ថែម៖

«ហេតុអ្វីយើងមិនគិតចង់ទិញផ្ទះនៅតំបន់សមុទ្រខ្លះ?»

«ដើម្បីអ្វីទៅ? ពេលនេះយើងមាននៅស្រុកខ្មែរឯណា?»

«ចុះពីមុន? និយាយពីគ្រួសារអូន! គឺកាលពីបងប្រុសអូននៅរស់!»

«ហ្នឹងរឹតតែមិនដឹងឆ្លើយយ៉ាងណា ព្រោះខ្ញុំនៅតែរៀន ហើយមិនដែលដឹងផងថាបងកុសលមានដីមានផ្ទះនៅឯណាខ្លះ!»

នាងចាប់ចំណិតសាច់ដាក់ទៅឱ្យគេ ហើយគេក៏លើកសម និងកាំបិតមក។

ដៃចាប់អាហារផង គេឈ្ងោកមុខនិយាយបន្ត៖

«ទៅកំពង់សោមជាមួយគ្នាអត់?!»

«ចាំអូនទៅតាមក្រោយ! អូនរៀបចំចាត់ចែងរឿងត្រៀមធ្វើបុណ្យបង្សុកូលជូនបងកុសលរួចសិន!» មេធាវីញញឹមភ្នែកដៀងសម្លឹងកែវទឹកក្រូចស្រស់ដែលនាងហុចមក គេមិនមាត់មិនក ប៉ុន្តែរឿងមួយចំនួនរត់រសឹបក្នុងសតិអារម្មណ៍គេ។

«អូនឡើងយកកាបូបណា៎! ជូនអូនដើរផ្សារមែនអត់?»

គេញញឹមងក់ក្បាលធ្វើឱ្យភរិយារីករាយ ក្រោកចេញចោលតុអាហារ។

«អូនមកវិញឥឡូវហើយ!»

នាងចាកចេញគេចាប់ផ្តើមរាវរកទូរសព្ទ....

«ខ្ញុំទៅកំពង់សោមម្នាក់ឯង! ខ្ញុំត្រូវការឱ្យឯងមកជូនខ្ញុំទៅកូនផ្ទះនោះ!»

«អ្ហូ! ចៃដន្យជំទាវម្នាក់ជួលខ្ញុំឱ្យចេញទៅថៃស៊ើបរឿងប្តីគាត់! តែចាំខ្ញុំទុកលេខផ្ទះលេខផ្លូវឱ្យ!»

មេធាវីនិយាយដោយទឹកមុខសោះកក្រោះ៖

«ខ្ញុំត្រូវការសោចាក់ចូលផ្ទះនោះ!»

អ្នកស៊ើបនៅស្ងៀម ជំនិតនិយាយបន្តដោយទឹកមុខក្រអឺតៈ

«អស់ប៉ុន្មានក៏ដោយ! យកសោមកឱ្យខ្ញុំ! មុនម៉ោង១០ព្រឹកស្អែក!»

«បាន!»

សំឡេងម្ខាងនោះឆ្លើយតបមកវិញយ៉ាងរហ័ស ព្រោះអំណាចពាក្យថា «អស់ប៉ុន្មានក៏ដោយ!»។ ជំនិតចុចបិទទូរសព្ទដោយទឹកមុខស្មើ។

នៅពីក្រោយចម្ងាយប្រមាណ១០ម៉ែត្រ ភីណាបង្ហាញខ្លួនជាមួយសំលៀកបំពាក់ដដែល តែប្តូរស្បែកជើងកែង និងកាបូបស្ពាយដ៏ស៊ីវិល័យពណ៌ស៊ីជម្ពូ អមជាមួយស្រស់ទឹកមុខស្រស់ស្រាយចិញ្ចាច។ គេញញឹមដាក់ភរិយា ហើយឈានតម្រង់ទៅក្បែរដៃនាងដើរមករករថយន្តដែលបញ្ឆេះរង់ចាំជាស្រេច។

«តាំងពីបងកុសលមានរឿង អូនមកភ្នំពេញប៉ុន្មានដង?!»

គេនិយាយតិចៗ តែភីណាទម្លាក់ទឹកមុខ នាងលើកវ៉ែនតាខ្មៅមកបាំងបិទភាពក្រៀមស្រពោនលើផ្ទៃមុខ។

«ម៉េចក៏មួយព្រឹកនេះ បងនិតសួរទាក់ទងតែរឿងមិនសប្បាយចិត្ត?»

«អូខេ! បាន! អញ្ចឹងប្តូរប្រធានបទទៅ!»

«យប់មិញឃើញបងនៅធ្វើអីដល់យប់ម៉េះ?!»

«ពីអង្កាល់?!»

«ម៉ោងជិត១២យប់ហើយ នៅក្រោកក្រាកក្បែរកុំព្យូទ័រ?»

«ពួកម៉ាកនៅអាមេរិកគេឆាតមកលេង!»

«ប្រាប់គេទៅថាស្រុកខ្មែរ គឺពាក់កណ្តាលអធ្រាត្រ!»

នាងនិយាយដោយបួញមាត់មិនសប្បាយចិត្ត។

ជំនិតលលេងវិញដោយគ្រឹតក្នាញ់៖

«ហើយប្រពន្ធអ្នកណាគេ កាចម៉េះ?!»

ភីណាមិនទាន់បានតបយ៉ាងណាផង ស្រាប់តែឡានបង្ខិលចង្កូតឃ្លេងឃ្លោង ហើយជាន់ហ្វ្រាំងផឹតស្ទើរហើបគូទពីកៅអី។

ជំនិតជ្រួញចិញ្ចើម ស្រវាឱបភរិយា។

រថយន្តឈប់ង៉ក់ ដោយសូហ្វ័រឡានធ្វើមុខស្មើក ព្រោះរថយន្តមួយមកពាំងពីមុខជាប់ រកលេសចាកចេញពីទីកើតហេតុក៏មិនបាន។

ស្នូរគោះកញ្ចក់តុៗ បង្ខំឱ្យសូហ្វ័ររវៃកញ្ចក់ទទួលយកនូវវាចាម៉ឹងម៉ាត់មួយឃ្លាលាន់មកពីខាងក្រៅ

៖

«បងបើកឡានខុសហើយ! ចុះមកសិនឱ្យប៉ូលិសធ្វើការ!»

ពាក្យថា «ប៉ូលិស» ធ្វើឱ្យគូស្វាមីភរិយាពលរដ្ឋអាមេរិកមិនសប្បាយចិត្តស្រាប់ហើយ តែសំឡេងនេះហាក់ដូចជាធ្លាប់ស្គាល់ ធ្វើឱ្យភីណាងើបមុខចេញពីទ្រូងប្ដីសម្លឹងទៅអ្នកដែលបង្ហោះសម្ដីរំលងកញ្ចក់ឡាននោះ។

នាងនៅទ្រឹង គ្រាដែលកែវភ្នែកសម្លឹងទៅប៉ះបុរសសម្បុរស្រអែមពុកចង្ការឹមៗ ដែលនាងខានឃើញគេជាច្រើនឆ្នាំមកហើយ។

ខ្សែភ្នែកគេក៏បានឈប់ង៉ក់ និមិត្តតែសម្លឹងមកបាំងខាងក្រោយ ហើយឃើញនាង។

ដៃនាងដែលកំពុងឱបក្រសោបស្វាមី ព្រោះភិតភ័យមុននេះ បានទម្លាក់ចេញមកវិញភ្លឹប ធ្វើឱ្យជំនិតងឿងឆ្ងល់ចំពោះប្រតិកម្មរបស់ភរិយា ហើយចង់មិនចង់ គេត្រូវតែងើបមុខសម្លឹងមើលទៅមនុស្សម្នាក់ដែលអាចធ្វើឱ្យភីណាអៀនប្រៀន មិនហ៊ានសូម្បីតែបន្តឱបប្ដីពេញច្បាប់របស់នាង។

....បេះដូងបុរសខ្មែរអាមេរិករំញោច ហាក់ត្រូវបុកនឹងវត្ថុអ្វីមួយដែលមិនមែនឈឺចាប់ តែក៏មិនស្រណុកសុខប្រាណ។

ផ្ទៃមុខបុរសខ្មែរមាឌក្រអាញដែលនៅចំពោះមុខគេ ប្រាកដណាស់   គឺជាបុរសម្នាក់ដែលគេឧស្សាហ៍ចូលស៊ើបឯកសារកាលប្រវត្តិ ស៊ើបគ្រប់យ៉ាងដែលទាក់ទងនឹងបុគ្គលនេះជារឿយៗ។

សំណួរស្វ័យប្រវត្តិមួយលេចឡើងក្នុងផ្នត់គំនិតដែលកំពុងចោមព័ទ្ធដោយព្រនង់នៃភាពភ្ញាក់ផ្អើល «ផែនដីនេះចង្អៀតដល់ម្លឹងអ្ហេះ?!»

សូហ្វ័រឡានវ័យក្មេងដែលមិនដឹងថា ទាំងអ្នកដែលបិទផ្លូវគាត់ និងអ្នកជិះក្នុងឡានធ្លាប់ស្គាល់គ្នាមានប្រវត្តិពាក់ព័ន្ធកម្រិតណាផងនោះ គេខំសម្រួលស្ថានការណ៍ដោយបានបើកទ្វារចុះមកតវ៉ាយករួចខ្លួន.....

«ខ្ញុំបើកឡានខុសត្រង់ណា?! មកពីរ៉ឺម៉កមួយនោះបានជា.....»
«ចាំទៅនិយាយគ្នានៅការិយាល័យប៉ូលិសចរាចរណ៍!»
គេនិយាយកាត់មកវិញស្មើៗ ជាសញ្ញាគ្មានមនោសញ្ចេតនា និងគ្មានពេលវេលាទុកឱ្យអ្នកបើកបរដោះសាឡើយ។
ឃើញទឹកមុខសោះកក្រោះរបស់គេ សូហ្វ័រឡានរវេត្នែកសម្លឹងទៅរកឋានន្តរសក្តិលើស្មាគេ និងឯកសណ្ឋានរបស់គេ ហើយក៏នៅស្ងៀមលែងហានិយាយអ្វីបាន។
ស្នូរទ្វារឡានខាងក្រោយបើកមកខ្វាក នាំយកនូវរូបរាងមេធាវីអាមេរិកដើមកំណើតខ្មែរ បង្ហាញខ្លួនបន្ទាប់ពីការដោះសារបស់អ្នកបើកបរមិនបានផល។
«សួស្តីឧត្តមសេនីយ៍ត្រីសេត វិទូ!»
នាយប៉ូលិសដែលចោមរោមដោយមនុស្សម្នា ហៀបនឹងនិយាយទៅកាន់ប៉ូលិសចរាចរណ៍ពីរនាក់ដែលទើបនឹងជ្រែកហ្វូងមនុស្សដើរមកដល់ គេផ្អាកកាយវិការងាកមកវិញភ្លាម។ គេនិយាយដោយទឹកមុខស្មើៗ៖
«អរគុណដែលស្គាល់ឈ្មោះខ្ញុំច្បាស់!»
«លោកបំបែកសំណុំរឿងល្បីៗ មានគេនិយាយលេចឮតាំងពីក្នុងរហូតដល់សមាគមខ្មែរក្រៅប្រទេស មានរឿងអីខ្ញុំចំណាំលោកមិនបាន?»
វិទូសម្លឹងបុរសមេធាវីដែលមានឫកពាជាបញ្ញវន្តសុភាពរាបសារ តែអ្នកហាក់បានរកឃើញភាពក្រអឺតក្រទមមួយលបលួចបង្កប់មកជាសម្ងាត់ ក្នុងកែវភ្នែករបស់គេដែលសម្លឹងមកខ្លួន។ នាយប៉ូលិសយើងវេត្នែកទៅរកស្រីស្រស់សោភា ដែលទើបតែងើបចេញពីក្នុងឡានមកនៅពីក្រោយបុរសក្រអឺតក្រអោងនោះ។
ភីណានិយាយតិចៗទៅកាន់បុរសដែលកំពុងសម្លឹងនាង ហើយមិនមាត់មិនក៖
«បងសុខសប្បាយទេ?»
វិទូងក់ក្បាលតិចៗ ក្នុងពេលបេះដូងមេធាវីរំជើបរំជួល។
«បើពួកគេខឹងគ្នា មិនសមណានិយាយរកគ្នាស្រួលៗ ហើយដូចជាបង្កប់ទុកនូវក្តីនឹករលឹកធំធេងចំពោះគ្នាដល់ថ្នាក់និយាយមិនចេញរៀងខ្លួន?»
ជំនិតគិតផង សម្លឹងមុខអតីតគូដណ្តឹងរបស់ភរិយាខ្លួន។
ភីណានិយាយបន្ថែមស្រាលៗ៖
«គាត់ទើបតែខុសលើកទីមួយ! បងកុំរករឿងគាត់ធ្វើអី!»
វិទូនៅស្ងៀម ងាកសម្លឹងអ្នកបើកបរដែលធ្វើមុខហាក់ដឹងកំហុស។ ជាមួយកែវភ្នែកស្រពោនរបស់

នាយប៉ូលិសយើង មេធាវីជំនិតសើចចុងមាត់ ហើយនិយាយបន្ថែមទៅកាន់អ្នកបើកបរ៖

«យើងជាអ្នកខុស! ទៅទទួលការផាកពិន័យទៅ!!»

សូហ្វ៊ុរឡានធ្វើមុខហួសចិត្ត ដែលមេធាវីនេះមិនសមថាមិននៅខាងខ្លួននោះទេ តែគេបានត្រឹមជ្រប់មុខ។

ជំនិតងាកមករកភរិយា ហើយនិយាយទៅកាន់នាង៖

«អូនកុំនាំឱ្យគាត់ពិបាក! ធ្វើប៉ូលិស គឺអនុវត្តិច្បាប់!»

តើសម្ដីនេះមានចេតនាឱ្យភីណានឹកត្រឡប់ទៅវិញដល់គ្រាមួយដែលវិទូវាយខ្នោះបញ្ជូនបងនាងឡើងតុលាការ ហើយចុងក្រោយគាត់មិនអាចទទួលយកការអាម៉ាស់នោះបាន ក៏ធ្វើទារុណកម្មខ្លួនឯងរហូតដល់ស្លាប់?»

នាងក៏ដឹងដែរថាគេជាមនុស្សរបៀបណា។

គេមិនទុកសូម្បីតែបងប្រុសនាងផង កុំថាឡើយមកឱ្យគេមកឃើញមនុស្សល្មើសច្បាប់ ហើយដោះលែងកណ្ដាលចំណោម។

ស្រីតូចក្រពាត់ដៃ ទឹកមុខនាងប្រែប្រួលទៅតាមការផ្លាស់ប្ដូរពណ៌សក់របស់នាងដូច្នេះដែរ។

«រឿងតូចទេ! បើមនុស្សចង់ធ្វើឱ្យទៅជាធំ គឺវាធំហើយ!»

នាងនិយាយទាំងទោមនស្សគឺនាងបានចូលក្នុងស៊ែងដែលត្រូវបានបញ្ឆេះកំហឹង និងរំលឹកអតីតកាល។ វិទូមិនមាត់ គេរវេរភ្នែកចេញ ហើយងាកទៅរកប៉ូលិសចរាចរណ៍ទាំងពីរនាក់ដែលនៅក្បែរនោះគេនិយាយមួយៗ៖

«បង! ខ្ញុំជិះកាត់ទីនេះឃើញឡានខាងណេះបើកបំពានស្លាកសញ្ញាហាម ហើយរំលោភលើគំនូស! គាត់ទៅប៉ះរ៉ឺម៉កខាងណោះមុន ហើយខ្ញុំឈប់ឡានឃាំងពីមុខគាត់!»

ប៉ូលិសចរាចរណ៍លើកដៃគោរពនាយ ហើយពួកគេចាប់ផ្ដើមធ្វើការវាស់វែង។ វិទូងាកមករកនារីដែលនាយធ្លាប់មាននាងពេញក្នុងបេះដូង។

នាងក្រពាត់ដៃធ្វើមុខស្មើ ស្វាមីនាងវិញខំលួងលោមក្នុងកាយវិការសុភាពបុរស៖

«មិនអីទេ! ចាំបងខលហៅសិក្ខាមក!»

គេចុចទូរសព្ទចំពេលវិទូនិយាយស្រាលៗមកកាន់ភីណាកាត់ពីមុខគេ៖

«សុំទោស! គាត់ធ្វើខុស ឱ្យគាត់ទទួលខុសត្រូវជាមួយច្បាប់ទៅ!»

ភីណាខាំបបូរមាត់តិចៗ នាងមិនងាកមើលសូម្បីតែមុខនាយជាសញ្ញាបង្ហាញថានាងមិនចង់សូម្បីតែពិចារណាហេតុផលដែលនាយពន្យល់មក។

វិទូសម្លឹងនាងម្ដងទៀត មុនពេលញញឹមគួរសមទៅកាន់ស្វាមីនាង ហើយចាកចេញទៅ។.....

# ផ្ទះតូចនៅសង្កាត់ស្ទឹងហាវ

....ជំនិតបានមកដល់ខេត្តព្រះសីហនុនៅម៉ោងប្រមាណជា៣រសៀល ហើយគេមិនចំណាយពេលច្រើនប៉ុន្មានឡើយក្នុងការរុករកកូនផ្ទះតូចតាមសេចក្ដីរាយការណ៍របស់អ្នកស៊ើបឯកជននោះ។

....កូនផ្ទះដែលគ្មានផ្លាកលេខ គ្មានសញ្ញាសម្គាល់ ប៉ុន្តែនៅប្រមាណ៥០ម៉ែត្រពីផ្លូវថ្នល់ គឺស្ថិតនៅក្នុងខណ្ឌស្ទឹងហាវដែលជាតំបន់ស្ងប់ស្ងាត់មួយ លំអរដោយទេសភាពស្រស់ត្រកាល។

មេធាវីរូបនេះរុញរបងឈើកម្ពស់ត្រឹមចង្កេះចូលទៅបរិវេណខាងក្នុងយ៉ាងស្រួល ព្រោះគ្មានការចាក់រនុកអ្វីពីក្នុងទេ។

ដៃគេរាវរកកូនសោផ្ទះដែលប្រើលុយទៅយកមកបាននោះ ភ្នែកក៏រេសម្លឹងជុំវិញខ្លួនដោយប្រុងប្រយ័ត្ន។ គ្មានអ្នកណាម្នាក់នៅទីនេះទេ សូម្បីតែសត្វចតុប្បាទមួយក៏គ្មាន គឺលាន់ឮមកតែសូររលកបោកផ្ទប់ច្រាំង និងបក្សាបក្សីច្រៀងកំដរស្រងេះស្រងោច។

ជំនិតបែរមុខត្រឡប់ទៅរកទ្វារឈើនៃកូនផ្ទះថ្មតូចច្រឡឹង ហើយមានតែជណ្ដើរថ្ម បីថ្នាក់ ក៏អាចឡើងទៅដល់បានស្រេចទៅហើយ។

នៅក្បែរជណ្ដើរ មានដើមផ្កាមួយចំនួនដាំតម្រៀបគ្នាជាជួរ ចោលសម្រស់ចម្រុះពណ៌គួរឱ្យគយគន់ក្រៃលែង។

ម្ចាស់ផ្ទះជាមនុស្សស្រីពិតគ្មានអ្វីចម្លែកឡើយ បើមើលទៅលើទិដ្ឋភាពអស់ទាំងនេះ។

....ចុះហេតុអ្វីនាងចាំបាច់លាក់កំបាំងនឹងប្ដី?

.....ទីនេះរៀបរយល្អ ស្អាតឯផ្កាក៏រីកស្គុះស្គាយ ប្រាកដជាមានអ្នកមកថែទាំជាប្រចាំ? តើនាងពិតជាបានឱ្យប្រាក់ឈ្នួលដល់អ្នកបម្រើឡើងចុះមកមើលទីនេះ ឬមួយនាងមានអ្នកផ្សេងណានៅក្បែរៗនេះចាំការពារថែទាំឱ្យ?

ប៉ុន្តែសំណួរទាំងប៉ុន្មានខាងលើ ក៏គ្មានអ្វីសំខាន់ស្មើទៅនឹងចម្ងល់ចុងក្រោយនេះដែរ... តើហេតុអ្វីបានជានាងចាំបាច់រក្សាទុកកូនផ្ទះមួយយ៉ាងអាថ៌កំបាំង ហើយចំណាយប្រាក់កាសថែទាំព្រមទាំងលាក់កំបាំងសូម្បីតែប្ដីមកធ្វើការទីនេះ ហើយក៏មិនឱ្យសោចូលទៅស្នាក់នៅ?
មុនពេលឈានជើងឡើងលើជណ្ដើរកាំទីមួយ គេងាកឆ្វេងស្ដាំសាជាថ្មី ហើយពន្លឿនសកម្មភាពទៅដល់ទ្វារឈើយ៉ាងរហ័ស ហើយស៊កសោចូលទៅ។

.....ទ្វាររបើកទៅខាងក្នុងនាំមកនូវក្លិនផ្អួរ និងលំអងធូលីតូចៗដណ្ដើមគ្នាហោះបង្ហើរទ្រលោមតាមរយៈពន្លឺព្រះអាទិត្យឆ្លុះទៅនឹងស្លាបព្រិលតូចៗ។

....ផ្ទះនេះពិតជាត្រូវបានទុកចោលដោយគ្មានអ្នករស់នៅមែន ចំណែកទិដ្ឋភាពខាងក្នុងរឹតតែមិនសក្តិសមថាជាកម្មសិទ្ធិរបស់ភីណា ទាយាទតែម្នាក់គត់ដែលស្នងមរតកនៃត្រកូលសេដ្ឋីមានទ្រព្យធន

ជាច្រើនក្នុងដៃនោះឡើយ។

....មកពីអញ្ចឹងដឹង បានជានាងមិនឱ្យប្ដីមកសម្រាកនៅកន្លែងនេះ? ឬមួយនាងមានអចលនវត្ថុជាកម្មសិទ្ធិច្រើនពេក រហូតវង្វេងភ្លេចផ្ទះដ៏តូចមួយនេះ ប៉ុន្ដែហេតុអ្វីបានជានាងចាំបាច់ត្រូវរក្សាវាទុក បើវាគ្មានអ្វីគួរឱ្យចាប់អារម្មណ៍ផង?

....គេរវើ្ភកសម្លឹងជុំវិញខ្លួន ហើយបញ្ឈប់នៅត្រង់គ្រែតូចមួយធ្វើពីឈើបេងរលោងស្រិល។ គ្រែនោះគ្មានពូកខ្នើយទេ បែរជាមានសៀវភៅមួយគំនរ។

....ជំនិតដើរតម្រង់ទៅ តែភ្នែកបានវាត់ទៅអានប៉ះសៀវភៅដំបូងគេដែលនៅពីលើនោះស្រេចទៅហើយ។

«ភីណាចូលចិត្តអានសៀវភៅច្បាប់អស់នេះពីពេលណាមក?»

គេរវើ្ភកតម្រង់រកសៀវភៅទីពីរ ហើយទីបី ល្មមពេលគេលូកដៃដល់។

សៀវភៅនីមួយៗក្រាលគ្របទៅដោយធូលីតូចៗល្អិត តែវាមិនបានរារាំងចិត្តសង្ស័យរបស់មេធាវីអាណិកជនឡើយ។

«កុំប្រាប់ថា ម្នាក់នោះធ្លាប់មកដេកមើលសៀវភៅកន្លែងនេះដែរណ៎ា!?»

ពន្លឺភ្នែកសៅហ្មងជះចេញមកលើសៀវភៅច្បាប់ទាំងតូចធំ ហើយគេទម្លាក់សៀវភៅដែលស្ថិតនៅលើដៃនោះចោលផាំងត្រឡប់ទៅលើគ្រែ។

មេធាវីបែរទៅរកទិសដៅផ្សេង តែមិនយូរប៉ុន្មានគេត្រឡប់មកកន្លែងដើមវិញដោយឱនសម្លឹងក្រោមគ្រែ។

....ទឹកមុខគេផ្លាស់ប្ដូរ....

....ជំនិតឱនខ្លួនចុះ ហើយមួរដៃអាវលូកទៅក្រោមគ្រែ ទាញយកចេញមកនូវរបស់អ្វីម៉្យាងហត់គយូស។ វាជាហិបឈើរាងទ្រវែងមួយកម្ពស់ប្រមាណពីរចំអាមមនុស្សប្រុស ប៉ុន្ដែបណ្ដោយប្រវែងប្រហែលជា៧ទៅ៨តឹក ឯទទឹងពី បីទៅបួនតឹក។

វាប្រាកដជាធ្ងន់បានជាគេទាញវាចេញមកដោយយឺតៗ។

....ផាំង.... គេវាយបំបាក់សោដ៏តូចស្ដើងដែលចាក់ភ្ជាប់ស្រយូវនៃហឹបឈើ។ បំណាច់តែបានចំណាយពេលជាច្រើនមកដល់ទីនេះហើយ សោនោះម៉េចនឹងអាចឃាត់ឃាំងសន្ទុះចិត្តចង់ដឹង ចង់ឮរបស់នាយបាន?

«ដោយសារអារបស់របរអស់នេះ នាងសុខចិត្តកុហកប្ដី?»

គេរអ៊ូជាមួយនឹងទឹកមុខដែលស្ដែងថាអស់កម្លាំងកាយ កម្លាំងចិត្ត។

នៅចប់តាមផ្លូវពីអាមេរិកមកដល់ស្រុកខ្មែរ ពីភ្នំពេញដល់ខេត្តឆ្នេរសមុទ្រនេះ គេតែងប្រាប់ខ្លួនឯងថា អ្វីៗខុសស្រឡះពីការសន្និដ្ឋានរបស់អ្នកស៊ើប។ ប៉ុន្តែពេលនេះ....

...ដាក់បង្គុយផ្ទាល់ទៅលើឥដ្ឋ ហើយចាប់ផ្ដើមពិនិត្យអ្វីៗទាំងអស់នៅក្នុងហិបនោះម្ដងមួយៗ.... ចុងក្រោយបុរសដែលប្រកបដោយភាពស្រពាប់ស្រពោនក្នុងកែវភ្នែក បានក្រោកឈរឡើងជាមួយនឹង Flash Memory Stick មួយ។

ច្បាស់ណាស់គេនឹងរកមើលថាអ្វីទៅនៅក្នុងនោះ ដូចដែលគេកាច់បំបាក់សោហិបឈើដូច្នោះដែរ។